**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលារាជធានីភ្នំពេញ**

លេខ: ៦០ សជណ.ស

ការិយាល័យរដ្ឋបាល
ចូលថ្ងៃទី 06/08/10 ម៉ោង......
លេខ 1869......
អ្នកទទួល...... ហត្ថលេខា......
អ្នកប្រគល់...... ហត្ថលេខា......
បញ្ជូនទៅ......

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១០

# សេចក្តីជូនដំណឹង

## ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ ២០១០

អនុលោមតាមប្រកាសលេខ ៨៦១ សហវ.ប្រក.ពដ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០១០ និងសេចក្តីជូនដំណឹងលេខ ០០៩ សហវ.ពដ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១០ ។ ដូចនេះសាលារាជធានីភ្នំពេញ សូមជូនដំណឹងដល់គ្រប់ក្រសួង មន្ទីរ អង្គភាព ក្រុមហ៊ុន និងប្រជាពលរដ្ឋដែលជាម្ចាស់យានយន្តគ្រប់ប្រភេទឲ្យបានជ្រាបថា ៖ ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១០ ត្រូវអនុវត្តចាប់ពីថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១០ រហូតដល់ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១០ នៅតាមសាខាពន្ធដារខណ្ឌ និង ទីកន្លែង មួយចំនួនដូចខាងក្រោម ៖

I- **ខណ្ឌឫស្សីកែវ**

- នៅសាខាពន្ធដារខណ្ឌ ឫស្សីកែវ ផ្លូវជាតិលេខ ៥ សង្កាត់ ឫស្សីកែវ
- នៅអាគារ អតីតស្នាក់ការពន្ធដារខណ្ឌ ឫស្សីកែវ ផ្លូវជាតិលេខ៥ សង្កាត់ គីឡូម៉ែត្រលេខ៦
- នៅគល់ស្ពានជ្រោយចង្វាខាងកើត (ផ្លូវបំបែក ) សង្កាត់ ជ្រោយចង្វា
- នៅរង្វង់មូលផ្លូវចូល កាំកូ សង្កាត់ ទួលសង្កែ
- នៅមុខវត្តទួលសង្កែ ឬក្នុងវត្តទួលសង្កែ សង្កាត់ទួលសង្កែ
- នៅខាងកើតបញ្ជរបង់ប្រាក់ប្រមាណ ៥០ ម៉ែត្រ ផ្លូវ ស ឡា (ផ្លូវ ២០០៤) សង្កាត់ទឹកថ្លា ខណ្ឌ សែនសុខ
- នៅទល់មុខបណ្ណាល័យសម្តេច ហ៊ុន សែន សង្កាត់ទឹកថ្លា ខណ្ឌ សែនសុខ
- នៅផ្លូវលេខ ១៩៨៦ ទល់មុខសាលាខណ្ឌសែនសុខចាស់ សង្កាត់ភ្នំពេញថ្មី ខណ្ឌ សែនសុខ
- នៅផ្លូវ ២៧១ ទល់មុខផ្សារ ហេង លី សង្កាត់ទឹកថ្លា ខណ្ឌ សែនសុខ

II- **ខណ្ឌដូនពេញ**

- នៅសាខាពន្ធដារខណ្ឌដូនពេញ អាគារលេខ ១៦៦ វិថីខេមរៈភូមិន្ទ(ផ្លូវ១៣០) សង្កាត់ផ្សារកណ្តាល២
- នៅក្បែរប៉ុស្តិ៍នគរបាលរដ្ឋបាល សង្កាត់ ចតុមុខ
- នៅមុខស្ថានីយ៍រថភ្លើង សង្កាត់ ស្រះចក
- នៅដើមពោធិមុខក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) សង្កាត់ វត្តភ្នំ
- នៅអាគារលេខ ២៥ បេ ផ្លូវ ២១៤ សង្កាត់ បឹងរាំង

III- **ខណ្ឌ៧មករា**

- នៅអាគារ អតីតស្នាក់ការពន្ធដារខណ្ឌ ៧មករា ផ្លូវលេខ ១០៥ សង្កាត់ បឹងព្រលឹត
- នៅមុខវិទ្យាល័យបាក់ទូក សង្កាត់ វាលវង់
- នៅរង្វង់មូលវត្តសំពៅមាស សង្កាត់ បឹងព្រលឹត

IV- **ខណ្ឌមានជ័យ**

- នៅសាខាពន្ធដារខណ្ឌ អាគារលេខ ១៧០៧ ផ្លូវជាតិលេខ ២ សង្កាត់ ចាក់អង្រែក្រោម
- នៅអាគារលេខ ១៧ (អតីតស្នាក់ការពន្ធដារខណ្ឌ )ផ្លូវជាតិលេខ១ សង្កាត់ច្បារអំពៅ២
- នៅចំណតរថយន្តចាក់អង្រែ ផ្លូវជាតិលេខ២ សង្កាត់ចាក់អង្រែក្រោម
- នៅក្នុងវត្តសន្សំកុសល សង្កាត់ បឹងទំពុន
- នៅក្នុងសាលាសង្កាត់ ស្ទឹងមានជ័យ

V- ខណ្ឌចំការមន

- នៅសាខាពន្ធដារខណ្ឌចំការមនថ្មី អាគារលេខ ២៨ ផ្លូវលេខ ២៨៨ សង្កាត់ ផ្សារដើមថ្កូវ
- នៅអាគារលេខ ៣៦៦(អតីតស្នាក់ការពន្ធដារខណ្ឌ) វិថីព្រះសីហនុ (ផ្លូវ ២៧៤ ) សង្កាត់ អូឡាំពិក
- នៅទល់មុខស្ថានទូតសាធារណរដ្ឋប្រជាមានិតចិន មហាវិថីម៉ៅសេទុង(ផ្លូវ២៤៥) សង្កាត់ទួលស្វាយព្រៃ១
- នៅមុខវត្តទួលទំពូង មហាវិថីម៉ៅសេទុង សង្កាត់ ទួលទំពូង១
- នៅជាប់របងសណ្ឋាគារ កុងទីណង់តាល់ ផ្លូវ ព្រះមុនីវង្ស សង្កាត់ ទំនប់ទឹក
- នៅមុខវត្តលង្កា វិថីព្រះសីហនុ សង្កាត់ បឹងកេងកង១

VI- ខណ្ឌទួលគោក

- នៅសាខាពន្ធដារខណ្ឌទួលគោក អាគារលេខ ២៥ ផ្លូវលេខ ២៨៧ សង្កាត់ បឹងកក់ទី១
- នៅអាគារលេខ ២០២បេ(អតីតស្នាក់ការពន្ធដារខណ្ឌ)វិថីឧកញ៉ា ទេព ផន(១៨២)សង្កាត់ សង្កាត់ផ្សារដេប៉ូទី១
- នៅមុខសាលាមតេយ្យទឹកល្អក់ ២ វិថីឧកញ៉ា ទេព ផន( ផ្លូវ ១៨២ ) សង្កាត់ទឹកល្អក់ទី២
- នៅមុខវិទ្យាល័យ ជា ស៊ីមសាមគ្គី ផ្លូវ ២៧១ សង្កាត់ បឹងសាឡាង
- នៅមុខមជ្ឈមណ្ឌល ម៉ុងឌីយ៉ាល់ មហាវិថីម៉ៅសេទុង(ផ្លូវ២៤៥)សង្កាត់ ផ្សារដើមគរ
- នៅមុខវិទ្យាស្ថានប៉ាស្ទ័រ ផ្លូវលេខ ២៨៩ សង្កាត់ បឹងកក់ទី២
- នៅរង្វង់មូលរង់ទែនទួលគោក ផ្លូវ ៥១៤ កែង ផ្លូវ ៥១៦ (ជាប់សណ្ឋាគារ ប៊ីដ លែន) សង្កាត់បឹងកក់ទី១

VII- ខណ្ឌដង្កោ

- នៅសាខាពន្ធដារ ខណ្ឌ ដង្កោ អាគារលេខ ២៣៤ ផ្លូវលេខ២០០៧ (ខាងលិចឈាងខាងជើងសួន) សង្កាត់កាកាប
- ទល់មុខសាលាខណ្ឌដង្កោ (អាគារ អតីតស្នាក់ការពន្ធដារខណ្ឌ) ជាប់ផ្លូវសហព័ន្ធរុស្ស៊ី (ផ្លូវជាតិលេខ ៤) សង្កាត់កាកាប
- នៅមុខក្រុមហ៊ុន K.T.M.Co.Ltd រង្វង់មូលចោមចៅ (ផ្លូវជាតិលេខ៤) សង្កាត់ ចោមចៅ
- នៅមុខរោងចក្រ ហុងដា ផ្លូវវេងស្រេង សង្កាត់ ចោមចៅ
- នៅមុខសាលាឆទាន ខាងត្បូងសាលាសង្កាត់ ដង្កោ ជាប់ផ្លូវចំការដូងទៅជើងឯក

ដើម្បីទទួលបាននូវការបង់ពន្ធត្រឹមត្រូវ និងចៀសវាងការក្លែងបន្លំពីសំណាក់ជនខិលខូច ដូចនេះ ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះទាំងអស់ ត្រូវអញ្ជើញទៅបង់ពន្ធនៅកន្លែងដែលបានកំណត់ខាងលើ និងត្រូវបំពេញសំណុំបែបបទតាមការណែនាំរបស់មន្ត្រីពន្ធដារ ។ ចំពោះករណីមានមន្ត្រីពន្ធដារ ឬ ជនខិលខូចដែលឆ្លៀតឱកាសលួចប្រមូលពន្ធក្រៅទីតាំងដែលបានកំណត់ខាងលើ អាជ្ញាធរខណ្ឌ សង្កាត់ កម្លាំងនគរបាល និងកងរាជអាវុធហត្ថរៀបចំសំណុំឯកសារ និងរាយការណ៍មកសាលារាជធានីភ្នំពេញ ដើម្បីដោះស្រាយតាមច្បាប់ជាធរមាន ។

សាលារាជធានីភ្នំពេញមានជំនឿជឿជាក់ថា គ្រប់ក្រសួង មន្ទីរ អង្គភាព ក្រុមហ៊ុន និងប្រជាពលរដ្ឋ ដែលជាម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះទាំងអស់ នឹងយកចិត្តទុកដាក់បំពេញកាតព្វកិច្ចសារពើពន្ធបានល្អជាមិនខាន ។

អភិបាលរាជធានីភ្នំពេញ

កែប ជុតិមា

**កន្លែងទទួល**

- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសាធារណៈការ និងដឹកជញ្ជូន

"*ដើម្បីជូនជ្រាប*"

- គ្រប់មន្ទីរ

អង្គភាពជុំវិញសាលារាជធានីភ្នំពេញ

- គ្រប់សាលាខណ្ឌ

"*ដើម្បីមុខការ*"

- គ្រប់ស្ថានីយ៍វិទ្យុ-ទូរទស្សន៍

"*ដើម្បីជួយផ្សព្វផ្សាយ*"

- កាលប្បវត្តិ-ឯកសារ